-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសអោយប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ

**សំរេច**

**មាត្រា ១.-**

ត្រូវបានប្រគល់ **មេដាយមាសស្ថាបនាជាតិ** ជូនអង្គការ **ភាពញញឹមនៃកុមារ** ដែលបានជួយកសាងអាគារសិក្សាមានពីរជាន់មួយខ្នង ជូនសាលាបឋមសិក្សា ស្ទឹងមានជ័យ សង្កាត់ស្ទឹងមានជ័យ ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ ចំណាយអស់ទឹកប្រាក់ ចំនួន ៧០.៦៩៤ ដុល្លារអាមេរិក ។

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា និងប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែមករា ឆ្នាំ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

====

## ២.សេចក្តីសំរេច

រាជធានីភ្នំពេញ, ថ្ងៃទី១២ ខែមករា ឆ្នាំ២០០១

**សេចក្តីសំរេចលេខ ០២ សសរ.**

**ស្តីពី**

**ការរៀបចំកិច្ចប្រជុំនៃក្រុមពិគ្រោះយោបល់លើកទី៥**

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

www.pheakdeylaw.com

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញអនុក្រឹត្យលេខ ២០/អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន

-បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៩៥ និងអនុក្រឹត្យកែសំរួល លេខ ៤៨ អនក្រ. ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-តាមសំណើរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាអនុប្រធានទី១ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## សំរេច

**ប្រការ ១ :** ប្រគល់ភារកិច្ចជូនឯកឧត្តម **គាត ឈន់** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុប្រធានទី១ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងការដឹកនាំ និងសំរបសំរួលការងារត្រៀមរៀបចំសំរាប់កិច្ចប្រជុំនៃក្រុមពិគ្រោះយោបល់លើកទី៥ ដែលនឹងប្រព្រឹត្តទៅក្នុងឆ្នាំ ២០០១ នេះ ។

**ប្រការ ២ :**

ក្នុងក្របខ័ណ្ឌនៃការដឹកនាំនិងសំរបសំរួលការងារត្រៀមរៀបចំសំរាប់កិច្ចប្រជុំនេះ ឯកឧត្តម **គាត ឈន់** ត្រូវសហការជាមួយប្រធាននៃបណ្តាក្រសួង និងស្ថាប័នទាំងអស់របស់រាជរដ្ឋាភិបាល និងមានសិទ្ធិអញ្ជើញមន្ត្រីជាន់ខ្ពស់ អោយចូលរួមប្រជុំអន្តរក្រសួង និងមានសិទ្ធិចាត់ចែង ពិគ្រោះយោបល់ជាមួយតំណាងប្រទេសនិងអង្គការអន្តរជាតិ អ្នកផ្តល់ជំនួយទ្វេភាគី និងពហុភាគី ដើម្បីសំរបសំរួលការងារ និងដើម្បីរៀបចំសេចក្តីព្រាងឯកសារចាំបាច់ៗនានា ។

**ប្រការ ៣ :**

ឯកឧត្តម **គាត ឈន់** ត្រូវរាយការណ៍ជាបន្តបន្ទាប់ជូនសម្តេចនាយករដ្ឋមន្ត្រី អំពីលទ្ធផលនៃការងារដែលបានបំពេញ ហើយត្រូវរៀបចំឯកសារចាំបាច់នានា សំរាប់កិច្ចប្រជុំលើកទី៥ នេះ ដើម្បីដាក់ជូនសម្តេចនាយករដ្ឋមន្ត្រី ពិនិត្យ ផ្តល់យោបល់ណែនាំ និងអនុម័តមុននឹងយកទៅប្រើប្រាស់ជាផ្លូវការ ។

www.pheakdeylaw.com

**ប្រការ ៤ :**

ក្នុងការបំពេញកិច្ចការនេះ ឯកឧត្តម **គាត ឈន់** ប្រើប្រាស់រចនាសម្ព័ន្ធរបស់គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា (កអក/គជនា) ដែលមានឯកឧត្តម **ឈឿង យ៉ាឆារ៉ា** ជាអគ្គលេខាធិការសំរាប់ជំនួយការងារប្រចាំថ្ងៃ ។

**ប្រការ ៥ :**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រី និងរដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងឯកឧត្តម **គាត ឈន់** ត្រូវអនុវត្តតាមសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រការ ៦ :**

សេចក្តីសំរេចនេះ មានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខារហូតដល់កិច្ចប្រជុំលើកទី ៥ នៃក្រុមពិគ្រោះយោបល់បានប្រព្រឹត្តទៅចប់សព្វគ្រប់ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

***

រាជធានីភ្នំពេញ, ថ្ងៃទី១៥ ខែមករា ឆ្នាំ ២០០១

## សេចក្តីសំរេចលេខ ០៣ សសរ.

## ស្តីពី

## ការបង្កើតគណៈកម្មការចំរុះអន្តរក្រសួង ដោះស្រាយបញ្ហារថយន្តចង្កូតសាំ

---

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

www.pheakdeylaw.com